ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លេខ ០០១/០៦ ម.ស.រ.ន.ព

# ព្រះសង្ឃប្រកាស
## ស្តីពី
## ការកំណត់បែងចែកភារកិច្ច សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី សម្តេចព្រះមហាសង្ឃរាជ និងសម្តេចព្រះមហាសុមេធាធិបតី ព្រះសង្ឃនាយក

សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី សម្តេចព្រះមហាសង្ឃរាជនៃព្រះរាជាណាចក្រកម្ពុជា
និងសម្តេចព្រះមហាសុមេធាធិបតី ព្រះសង្ឃនាយកនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា.
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៤០៦/២០០ ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៦ ស្តីពីការតែងតាំង ព្រះមហាសុមេធាធិបតី នេត ទន្ស សម្តេចព្រះសង្ឃរាជ គណៈមហានិកាយនៃព្រះរាជាណាចក្រកម្ពុជា ឱ្យឡើងព្រះឋានៈ ជាសម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី សម្តេចព្រះមហាសង្ឃរាជនៃព្រះរាជាណាចក្រកម្ពុជា.
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៥០៦/២០៧ ចុះថ្ងៃទី ០៤ ខែឧសភា ឆ្នាំ២០០៦ ស្តីពីការបង្កើត គណៈសង្ឃនាយក ដោយតម្លើងសម្តេចព្រះពោធិវង្ស នន្ទ ង៉ែត ឱ្យឡើងព្រះឋានៈជាសម្តេចព្រះមហាសុមេធាធិបតី ព្រះសង្ឃនាយកនៃព្រះរាជាណាចក្រកម្ពុជា.
- យោងតាមស្មារតីអង្គប្រជុំ ថ្ងៃទី ២១ ខែ សីហា ឆ្នាំ២០០៦ ស្តីពីដំណើរការប្រព្រឹត្តិទៅ នៃវិស័យព្រះពុទ្ធសាសនានៅព្រះរាជាណាចក្រកម្ពុជា.
- យោងតាមសំណូមពរ និងតម្រូវការចាំបាច់

## ស ម្រេ ច

ប្រការ ១- កំណត់បែងចែកព្រះភារកិច្ចថ្វាយ-ប្រគេន សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី នេត ទន្ស សម្តេចព្រះមហាសង្ឃរាជនៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចព្រះមហាសុមេធាធិបតី នន្ទ ង៉ែត ព្រះសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា ដូចតទៅនេះ :

ក/ ព្រះរាជភារកិច្ច សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី :

ក-១- ទទួលគ្រប់គ្រង និងដឹកនាំការងារព្រះពុទ្ធសាសនាក្នុងប្រទេស និងទំនាក់ទំនងការងារពុទ្ធសាសនានៅក្រៅប្រទេស ឱ្យប្រព្រឹត្ត ទៅប្រកបដោយកិត្តិយស សេចក្តីថ្លៃថ្នូរ ។

ក-២- ទទួលភារកិច្ចចុះព្រះហស្តលេខា លើប្រកាសនីយប័ត្រតែងតាំងព្រះសមុហ៍គណ ព្រះធម្មធរគណ ព្រះវិន័យធរគណ ព្រះបាឡាត់គណ ព្រះអនុគណ និងព្រះមេគណឡើងទៅ តាមបែបបទពីមូលដ្ឋាន និងតាមសំណើរបស់គណៈសង្ឃនាយក ដោយមានការយល់ព្រមពីសម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល ។

ក-៣- រាល់ការតែងតាំងតម្លើង ឬដកឋានៈគោរម្យងារ ជាទីប្រឹក្សា, ជារាជាគណៈកិត្តិយស, ជារាជាគណៈក្នុងងារ ឋានានុក្រម និងមុខងារផ្សេងៗ ពាក់ព័ន្ធដល់ព្រះរាជក្រឹត្យ ត្រូវធ្វើតាមសំណើរពីគណៈសង្ឃនាយក និងការយល់ព្រមពីសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល ។/.

ខ/ព្រះភារកិច្ចរបស់សម្តេចព្រះមហាសុមេធាធិបតី ព្រះសង្ឃនាយក

ខ-១- ទទួលភារកិច្ចស្តីទី ក្នុងការគ្រប់គ្រង និងដឹកនាំការងារពុទ្ធសាសនា ក្នុងឱកាសអវត្តមានសម្តេចព្រះអគ្គមហាសង្ឃ រាជាធិបតី សម្តេចព្រះមហាសង្ឃរាជនៃព្រះរាជាណាចក្រកម្ពុជា។

ខ-២- ចុះព្រះហស្ថលេខា លើប្រកាសនីយបត្រ តែងតាំងលោកគ្រូចៅអធិការ គ្រូសូត្រស្តាំ-ឆ្វេង ព្រះវិន័យធរ លេខាធិការ ព្រះឧបជ្ឈាយ៍ ព្រះវិន័យធរអនុគណ ព្រះធម្មធរអនុគណ ព្រះសមុហ៍អនុគណ ព្រះលេខាធិការអនុគណ តាមសំណើរបស់សមូហភាពសង្ឃនៃវត្តនីមួយៗ ដែលរួមមានទាំងព្រះអនុគណ ព្រះបាឡាត់គណ ព្រះមេគណ ដោយមានការយល់ព្រមពីអាជ្ញាធរមូលដ្ឋាន ស្រុក-ខ័ណ្ឌ និងខេត្ត-ក្រុង តាមរយៈក្រសួងធម្មការនិងសាសនា ដោយត្រូវរាយការណ៍ថ្វាយសម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី សម្តេចព្រះមហាសង្ឃរាជទ្រង់ជ្រាប។

ខ-៣- ទទួលព្រះភារកិច្ច ក្តាប់ការងារស្ថិតិវត្តអារាម ភិក្ខុ សាមណេរ អាចារ្យ គណៈកម្មការវត្ត កុមារ យុវជន ស្នាក់នៅក្នុងវត្ត នៅក្នុងទូទាំងប្រទេស បូកសរុបរាយការណ៍ថ្វាយសម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី សម្តេចព្រះមហាសង្ឃរាជ ការបើកអនុសំវច្ឆរៈមហាសន្និបាតមន្ត្រីសង្ឃប្រចាំឆ្នាំ ត្រួតពិនិត្យដំណើរការប្រព្រឹត្តទៅនៃវិស័យព្រះពុទ្ធសាសនា ក្នុងក្របខ័ណ្ឌកិច្ចការរដ្ឋបាល និងទំនាក់ទំនងសាធារណៈ។

ខ-៤- ទទួលព្រះភារកិច្ច ក្តាប់ការងារពុទ្ធិកសិក្សាគ្រប់កម្រិត ចាប់ពីពុទ្ធិកបឋមសិក្សារហូតដល់ពុទ្ធិកឧត្តមសិក្សា ក្នុងឋានៈជាអគ្គនាយកពុទ្ធិកសិក្សា និងជាពុទ្ធិកសាកលវិទ្យាធិការនៃពុទ្ធិកសាកលវិទ្យាល័យ ដោយត្រូវផ្តោតព្រះទ័យទៅលើការពង្រឹងគុណភាព នៅសាលាពុទ្ធិកបឋមសិក្សានៅថ្នាក់មូលដ្ឋាន មានបញ្ហាគ្រូ បញ្ហាសម្ភារៈបរិក្ខារ កម្មវិធីសិក្សា ។ល។ និងសាលាធម្មវិន័យទាំង៣ថ្នាក់ ។

ប្រការ ២- សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី សម្តេចព្រះមហាសង្ឃរាជ និងសម្តេចព្រះមហាសុមេធាធិបតី ព្រះសង្ឃនាយក មានមន្ត្រីសង្ឃ និងគ្រហស្ថមួយចំនួន ជាជំនួយការតាមតម្រូវការចាំបាច់ និងប្រើប្រាស់ត្រាជាផ្លូវការ តាមកម្រិតគោរម្យងារកំណត់រៀងៗព្រះអង្គ ។

ប្រការ ៣- សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី សម្តេចព្រះមហាសង្ឃរាជ និងសម្តេចព្រះមហាសុមេធាធិបតី ព្រះសង្ឃនាយកធ្វើការងារដោយសហការជិតស្និទ្ធ ក្នុងជំហរសាមគ្គីភាព ជាសហធម្មិកតាមភារកិច្ច ដែលបានកំណត់ឱ្យប្រព្រឹត្តទៅប្រកបដោយលទ្ធផលល្អប្រសើរ។

ប្រការ ៤- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា រដ្ឋមន្ត្រី រដ្ឋលេខាធិការពាក់ព័ន្ធ គ្រប់ខេត្ត-ក្រុង និងមន្ត្រីសង្ឃគ្រប់ជាន់ថ្នាក់ ត្រូវអនុវត្តតាមព្រះសង្ឃប្រកាសនេះ ។

ប្រការ ៥- បទប្បញ្ញត្តិទាំងឡាយណា ផ្ទុយពីព្រះសង្ឃប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៦- ព្រះសង្ឃប្រកាសនេះ មានប្រសិទ្ធភាព និងស្ថេរភាពចាប់ពីថ្ងៃចុះព្រះហស្ថលេខា និងហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែសីហា ព.ស ២៥៥០
គ.ស ២០០៦

លេខ : ០១ (ស-ត)

បានឃើញ និងឯកភាព
រាជធានីភ្នំពេញ.ថ្ងៃទី២៤ ខែ ៧ ឆ្នាំ២០០៦
នាយករដ្ឋមន្ត្រី

ហ៊ុន សែន

សម្តេចព្រះមហាសុមេធាធិបតី
ព្រះសង្ឃនាយក

នន្ទ ង៉ែត

សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី
សម្តេចព្រះមហាសង្ឃរាជ

តេព វង្ស

**ចម្លងជូន**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- ឯកសារ-កាលប្បវត្តិ